ចំពោះដែលអ្នកទើបបានទទួលមេឌីខាលថ្មី **Medi-Cal CHDP Gateway**, តើអ្វីខ្លះដែលអ្នកត្រូវដឹង

បច្ចុប្បន្ននេះ កូនរបស់អ្នកមានការធានា៉ាប់រងសុខភាពពីមេឌីខាលដោយទទេជាបណ្ណោះអាសន្ន។
ការធានា៉ាប់រងលើ សុខភាពនេះមានសុពលភាពក្នុងខែនេះនិងនៅក្នុងខែបន្ទាប់មកពេញមួយខែ។

អ្នកអាចប្រើក្រដាសបំណ្ណមេឌីខាលដែលគ្លីនិករបស់អ្នកចម្លងចេញមកឲ្យ សម្រាប់ប្រើប្រាសដូចតទៅ: ទៅជួបគ្រូពេទ្យ ទិញថ្នាំដែលគ្រូពេទ្យចេញសំបុត្រឲ្យទិញ ការពិនិត្យថែទាំធ្មេញនិងការពិនិត្យថែទាំភ្នែក(វ៉ែនតា)។ ក្រដាសបំណ្ណនេះប្រើ ការបានដូចបំណ្ណមេឌីខាលធម្មតាដែរ។ បំណ្ណប្ចស្ទិកវ៉ែងមួយនឹងបញ្ចេញឲ្យអ្នក ២ថ្ងៃបន្ទាប់ពីបំណ្ណក្រដាសបានចេញឲ្យ។

សូមចំណាំទុកថា ការធានា៉ាប់រងសុខភាពនេះគឺបណ្ណោះអាសន្នទេ ទោះបីជាអ្នកបានទទួលបំណ្ណដែលផ្ញើទៅឲ្យអ្នក ក៏ដោយ។ ប្រសិនបើអ្នកមិនបានបំពេញក្រដាសពាក្យសុំទេ ការធានា៉ាប់រងសុខភាពមេឌីខាលរបស់កូនអ្នកនឹងត្រូវ បញ្ចប់។

ទារក (អាយុក្រោម១២ខែ)

មាតាៗ បើអ្នកមានមេឌីខាលនៅក្នុងដំណាក់កាលដែលអ្នកមានផ្ទៃពោះ ការបន្ថែមកូនអ្នកទៅក្នុងមេឌីខាលរបស់អ្នកជាការងាយស្រួល។ មានពីរយ៉ាងសម្រាប់បញ្ចូលទារករបស់អ្នកទៅក្នុងមេឌីខាលរបស់អ្នក:

១. ទូរស័ព្ទទៅអ្នកកាន់សំណុំរឿងមេឌីខាលរបស់អ្នក (EW) ហើយប្រាប់គាត់ថាអ្នកទើបសំរាលកូនរួច ហើយប្រាប់គាត់លេខមេឌីខាលបណ្ណោះអាសន្នដែលគ្លីនិកបានចេញឲ្យកូនអ្នក។

២. ទាក់ទងក្រសួងសុខាភិបាលនៅឡងប៊ីច ហើយគេនឹងជួយអ្នកក្នុងការដាក់ពាក្យសុំបញ្ចូលទារកទើបកើតថ្មីៗ។ អ្នក គ្រាន់តែយកបំណ្ណអនុសាវរីយ៏ឬបំណ្ណកំណើតនិងកាតសូស្យលសេគ្យរីទី ហើយនិងបំណ្ណមេឌីខាលបណ្ណោះអាសន ទៅជាមួយ។

បើអ្នកត្រូវការជំនួយដាក់ពាក្យសុំមេឌីខាលឬបញ្ចូលទារកទើបកើតរបស់អ្នក សូមទាក់ក្រសួងសុខាភិបាល។

LONG BEACH
HEALTH & HUMAN SERVICES
Child Health & Disability Prevention
CHDP

Department of Health and Human Services
2525 Grand Avenue
Long Beach, CA 90815
562-570-7979
Office hours: 8-5:00PM Monday-Friday

ដើម្បីព័ត៌មានបន្ថែម សូមទាក់ទងក្រសួងសុខាភិបាលឡងប៊ីច Long Beach CHDP Administration តាមលខទូរស័ព្ទ